ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ នាយកដ្ឋានទប់ស្កាត់ការរីករាលដាលនៃជំងឺរុក្ខជាតិ

# សេចក្តីជូនដំណឹងសំខាន់

## ដើម្បីនាំរុក្ខជាតិចូលទៅក្នុងប្រទេសជប៉ុន

## គឺចាំបាច់ត្រូវមានវិញ្ញាបនបត្រភូតគាមអនាម័យ

យោងទៅតាមច្បាប់ស្តីពីការទប់ស្កាត់ការរីករាលដាលនៃជំងឺរុក្ខជាតិ ដើម្បីនាំរុក្ខជាតិ*ចូលក្នុងប្រទេសជប៉ុនគឺចាំបាច់ត្រូវភ្ជាប់មកជាមួយនូវវិញ្ញាបនបត្រភូតគាមអនាម័យ (Phytosanitary certificate)ដែលចេញដោយស្ថាប័នរាជរដ្ឋាភិបាលនៃប្រទេសនាំចេញ ព្រមទាំងត្រូវទទួលការត្រួតពិនិត្យភូតគាមអនាម័យសម្រាប់ការនាំចូល។

រុក្ខជាតិមួយចំនួនត្រូវបានហាមឃាត់មិនឱ្យនាំចូលទៅក្នុងប្រទេសជប៉ុននោះទេ (សូមមើលទំព័រខាងក្រោយ)។

* ផ្លែឈើ បន្លែ គ្រាប់ធញ្ញជាតិជាដើម ក្រៅពីនេះក៏រួមមាន ផ្កាកាត់ ពន្លកឈើ និងផលិតផលកែច្នៃមួយចំនួនដែលប្រើប្រាស់រុក្ខជាតិធ្វើជាវត្ថុធាតុដើម។ ម្យ៉ាងទៀត ចំពោះរុក្ខជាតិខ្លះគឺមិនចាំបាច់មានវិញ្ញាបនបត្រភូតគាមអនាម័យនោះទេ (ចាំបាច់ត្រូវទទួលការត្រួតពិនិត្យភូតគាមអនាម័យសម្រាប់ការនាំចូល) ហើយក៏មានរុក្ខជាតិខ្លះដែលមិនចាំបាច់មានវិញ្ញាបនបត្រភូតគាមអនាម័យនិងទទួលការត្រួតពិនិត្យភូតគាមអនាម័យសម្រាប់ការនាំចូលនោះដែរ (សូមមើលទំព័រខាងក្រោយ)។

រុក្ខជាតិដែលគ្មានវិញ្ញាបនបត្រភូតគាមអនាម័យភ្ជាប់មកជាមួយគឺនឹងត្រូវបានកម្ចាត់ចោល ដោយផ្អែកទៅលើច្បាប់ស្តីពីការទប់ស្កាត់ការរីករាលដាលនៃជំងឺរុក្ខជាតិ។

ករណីអ្នកបាននាំចូលដោយគ្មានការភ្ជាប់មកជាមួយនូវវិញ្ញាបនបត្រភូតគាមអនាម័យ ឬ ករណីអ្នកមិនបានទទួលការត្រួតពិនិត្យភូតគាមអនាម័យនៅពេលនាំចូល អ្នកអាចនឹងត្រូវបានផ្តន្ទាទោសឱ្យជាប់ពន្ធនាគារ 3 ឆ្នាំចុះក្រោម ឬ ទទួលការផាក ពិន័យជាប្រាក់ 3 លានយេនចុះក្រោម (ករណីជានីតិបុគ្គលគឺ 50 លានយេនចុះក្រោម)។.

## រឹតបន្តឹងការទប់ស្កាត់ការជ្រៀតចូលនៃ សត្វល្អិតបង្កជំងឺរុក្ខជាតិ

MAFF
Ministry of Agriculture, Forestry and Fisheries
農林水産省

## រុក្ខជាតិសំខាន់ៗដែលត្រូវបានហាមឃាត់មិនឱ្យនាំចូលទៅក្នុងប្រទេសជប៉ុន

- បន្លែផ្លែឈើស្ទើរគ្រប់ទាំងអស់ (ប្រភេទផ្លែក្រូច ផ្លែស្វាយ ជាដើម) មកពីប្រទេសឬតំបន់ដែលកំពុងកើតមានសត្វ Mediterranean fruit fly ឬ សត្វ Oriental fruit fly
- ផ្លែប៉ោម ផ្លែឆេរី គ្រាប់វ៉លណាត់មានសម្បក ជាដើម មកពីប្រទេសឬតំបន់ដែលកំពុងកើតមានសត្វ Codling moth

*ក្រៅពីនេះក៏មានការហាមឃាត់ចំពោះការនាំចូលរុក្ខជាតិភាគច្រើនពីប្រទេសឬតំបន់ដែលកំពុងកើតមានសត្វល្អិតដែលផ្តល់ផលប៉ះពាល់ធំធេងលើពិភពលោក ទោះមិនទាន់កើតឡើងនៅប្រទេសជប៉ុន។ សម្រាប់ព័ត៌មានលម្អិត សូមទំនាក់ទំនងទៅកាន់នាយកដ្ឋានទប់ស្កាត់ការរីករាលដាលនៃជំងឺរុក្ខជាតិ។



សត្វ Mediterranean fruit fly



សត្វ Oriental fruit fly



សត្វ Codling moth

## រុក្ខជាតិដែលមិនចាំបាច់មានវិញ្ញាបនបត្រភូតគាមអនាម័យ
## ( ⚠ ចាំបាច់ត្រូវទទួលការត្រួតពិនិត្យភូតគាមអនាម័យសម្រាប់ការនាំចូល)

រុក្ខជាតិក្រៀមឬបង្កក ដូចជា ម្សៅម្ទេស ម្រេចជប៉ុន ឆៃថាវហាន់ក្រៀម ប៉ប្រក(Asian royal fern) យិនស៊ិន គ្រាប់ឈូក ប៉ូចកាក់(Star anise) គ្រាប់កាហ្វេស្រស់ គ្រាប់ផ្កាឈូករ័ត្ន(សម្រាប់បរិភោគ)ជាដើម ហើយជារុក្ខជាតិដែលមិនត្រូវបានប្រើប្រាស់នៅក្នុងការដាំដុះ ការធ្វើជាចំណីសត្វ ជី ឬវត្ថុធាតុសម្រាប់ផលិតកម្មក្នុងវិស័យកសិកម្មនិងព្រៃឈើ។

*សម្គាល់៖ ចំពោះរុក្ខជាតិប្រភេទធញ្ញជាតិ (អង្ករ ស្រូវមីយេ ពោត សូបា ប្រភេទស្រូវសាលី ជាដើម) ប្រភេទសណ្តែក(សណ្តែកសៀង សណ្តែកក្រហម សណ្តែកដី ជាដើម) វត្ថុធាតុឈើ សណ្តែកកាការ ល្ង ផ្លែអំពិលក្រៀម វ៉ាន់ស៊ុយ ផ្កាក្រៀមឬថ្នាំបុរាណឬគ្រឿងទេសមួយចំនួនជាដើម ទោះជាទាំងនេះគឺជារុក្ខជាតិក្រៀម ប៉ុន្តែក៏ចាំបាច់ត្រូវភ្ជាប់មកជាមួយនូវវិញ្ញាបនបត្រភូតគាមអនាម័យផងដែរ។ សម្រាប់ព័ត៌មានលម្អិត សូមទំនាក់ទំនងទៅកាន់នាយកដ្ឋានទប់ស្កាត់ការរីករាលដាលនៃជំងឺរុក្ខជាតិ។

## រុក្ខជាតិដែលមិនចាំបាច់ភ្ជាប់វិញ្ញាបនបត្រភូតគាមអនាម័យនិងទទួលការត្រួតពិនិត្យភូតគាមអនាម័យសម្រាប់ការនាំចូល

- ឈើកែច្នៃ
- តែកែច្នៃ
- រុក្ខជាតិដែលបានត្រាំនៅក្នុងអាល់កុល អាស៊ីតអាសេទិច ឬ ស្ករ ជាដើម

## លេខទូរសព្ទទំនាក់ទំនងសំខាន់ៗនៃនាយកដ្ឋានទប់ស្កាត់ការរីករាលដាលនៃជំងឺរុក្ខជាតិ


- នាយកដ្ឋានទប់ស្កាត់ការរីករាលដាលនៃជំងឺរុក្ខជាតិប្រចាំនៅYokohama
  ＋８１－４５－２１１－７１５３
- នាយកដ្ឋានទប់ស្កាត់ការរីករាលដាលនៃជំងឺរុក្ខជាតិប្រចាំនៅNagoya
  ＋８１－５２－６５１－０１１２
- នាយកដ្ឋានទប់ស្កាត់ការរីករាលដាលនៃជំងឺរុក្ខជាតិប្រចាំនៅKobe
  ＋８１－７８－３３１－２３８６
- នាយកដ្ឋានទប់ស្កាត់ការរីករាលដាលនៃជំងឺរុក្ខជាតិប្រចាំនៅMoji
  ＋８１－９３－３２１－２６０１
- ការិយាល័យទប់ស្កាត់ការរីករាលដាលនៃជំងឺរុក្ខជាតិប្រចាំនៅNaha
  ＋８１－９８－８６８－２８５０

ការពិគ្រោះយោបល់ https://www.contactus.maff.go.jp/j/pps/form/qa_e.html